**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ២៨៥២ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែឧសភា ឆ្នាំ ២០០៣

# ប្រកាស

## ស្តីពី

## ការបំពេញបន្ថែមអនុគណនីនៃគណនី ប្រាក់បញ្ញើរបស់សាលាខេត្ត ក្រុង

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ /នស/ ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ហើយត្រូវបានកែប្រែដោយច្បាប់គ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/រកម/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស /រកម/១២៩៩ /១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស /រកម/១២០២ /០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃ ទី ២៤ ខែមករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើព្រះរាជក្រមលេខ នស /រកម /១២០២ /០២១ ចុះថ្ងៃ ទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ/បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ០៤ អ.ន.ក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩៣៣ ប្រក.សហវ ចុះថ្ងៃ ទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការកែសំរួលប្លង់គណនេយ្យរដ្ឋ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## សំរេច

**ប្រការ ១** : ត្រូវបានបង្កើតជាអនុគណនីចំនួន ០៣នៃគណនីដើម "ប្រាក់បញ្ញើរបស់សាលាខេត្ត ក្រុង" ដែលមានលេខគណនី 424 ដូចមានចែងក្នុងប្រកាសលេខ ៩៣៣ ចុះ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការកែសំរួលប្លង់គណនេយ្យទូទៅនៃគណនេយ្យរដ្ឋ ។

អនុគណនីទាំង ០៣ បើកនៅធនាគាររាជធានីភ្នំពេញ ដែលមានឈ្មោះ លេខសំគាល់ និងប្រព្រឹត្តិកម្មដូចខាងក្រោម :

**ក-** អនុគណនី "ប្រាក់បញ្ញើរបស់សាលាក្រុងភ្នំពេញ ស្តីពីចំណូលដែលបានមកពីអាករបំភ្លឺសាធារណៈ" អនុគណនីមានលេខ **424.01**

**ខ-** អនុគណនី " ប្រាក់បញ្ញើរបស់សាលាក្រុងភ្នំពេញ ស្តីពីចំណូលដែលបានមកពីចំនួនទឹកប្រាក់ 10%ដែលអង្គភាពរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានបូកបន្ថែមនៅក្នុងវិក័យប័ត្រប្រើប្រាស់ទឹក " អនុគណនីមានលេខ **424.02**

**គ-** អនុគណនី " ប្រាក់បញ្ញើរបស់សាលាក្រុងភ្នំពេញ ស្តីពីចំណូលដែលបានមកពីចំណូលផ្សេងទៀតក្រៅពីប្រភពទាំងពីរខាងលើនេះ " អនុគណនីមានលេខ **424.03**

**ឃ-** ប្រព្រឹត្តិកម្មនៃអនុគណនីទាំងនេះ គឺកត់ត្រាដូចគណនីដើម លេខ **424** ដែរ ។

**ប្រការ ២** : ប្រាក់ចំណូលដែលបានមកពី អាករបំភ្លឺសាធារណៈត្រូវរក្សាទុកសំរាប់ធានាទូទាត់ចំណាយថ្លៃចរន្តអគ្គិសនីប្រើបំភ្លឺសាធារណៈទូទាំងរាជធានីភ្នំពេញ

ប្រាក់ចំណូលដែលបានមកពីការបូកបន្ថែមនៅក្នុងវិក័យប័ត្រប្រើប្រាស់ទឹក **10%** ត្រូវរក្សាទុកសំរាប់ធានាទូទាត់ចំណាយថ្លៃចរន្តអគ្គិសនីប្រើសំរាប់ បូមទឹកកខ្វក់ចេញទៅក្រៅក្រុង ចំណាយជួសជុល កសាងប្រព័ន្ធលូបង្ហូរទឹកកខ្វក់ ។

**ប្រការ ៣** : ប្រាក់ចំណូលដែលបានកត់ត្រានៅក្នុងអនុគណនី **424.01** , **424.02** ខាងលើ អាចប្រើប្រាស់ជាគុណប្រយោជន៍ផ្សេងទៀតរបស់សាលាក្រុង គឺក្រោយពីបានបំពេញកាតព្វកិច្ចធានាចំណាយដូចមានចែងក្នុងប្រការ ២ ខាងលើ ។

**ប្រការ ៤** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋានទ្រព្យរដ្ឋ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ច ប្រធានរតនាគារជាតិ និងអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

***ចំលងជូន*** :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  "ដើម្បីជូនជ្រាប"
- សាលាក្រុងភ្នំពេញ
- ដូចប្រការ ៤
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ